

# ព័ត៌មានទាន់ហេតុការណ៍

The Asia Foundation - Let’s Read



វ៉ាណាចូលចិត្តតាមដានរឿងរ៉ាវអាថ៌កំបាំងណាស់ ទាំងរឿងនៅសាលា និងជាពិសេសពេលដែលនាងលេងជាមួយមិត្តភក្តិនៅខាងក្រៅ។ ប៉ុន្តែម្តាយរបស់វ៉ាណាចង់ឱ្យនាងស្វែងយល់ពីរឿងរ៉ាវអាថ៌កំបាំងតែនៅក្នុងថ្នាក់រៀនប៉ុណ្ណោះ ព្រោះវាមិនធ្វើឱ្យប្រឡាក់សំពត់អាវរបស់នាង។



«រ៉ាណាកូន! មកញ៉ាំបាយ!» ម្ដាយរ៉ាណា ស្រែកហៅនាងពីក្នុងផ្ទះ។



នៅពេលវ៉ាណាកំពុងដើរចូលក្នុងផ្ទះ នាងស្តាប់ឮសំឡេងស្ត្រីម្នាក់ចេញពីក្នុងទូរទស្សន៍។ «នេះជាព័ត៌មានទាន់ហេតុការណ៍! នៅមុននេះបន្តិច មានករណីចោរកម្មមួយទៀតហើយ ដែលបានកើតឡើងក្នុងផ្សារមួយដែលស្ថិតនៅជាយក្រុង។ អ្នកទិញ និងអ្នកលក់ ត្រូវមានការប្រុងប្រយ័ត្នបន្ថែមទៀតចំពោះសម្ភារៈរបស់ខ្លួន។»



វ៉ាណាសួរម្ដាយថា៖ «ម៉ាក់! តើមីងម្នាក់ដែលនៅក្នុង ទូរទស្សន៍នោះ អាចដឹងព័ត៌មានដែលកើតឡើងនៅផ្សារ ដោយរបៀបណា?» ម្ដាយវ៉ាណាឆ្លើយថា៖ «គាត់គឺជា អ្នកសារព័ត៌មាន។ ការងាររបស់គាត់ គឺត្រូវស្វែងរក និងសួរនាំ រឿងរ៉ាវពីប្រភពផ្សេងគ្នាដើម្បីប្រមូលព័ត៌មាន ថតរូបភាព និង វីដេអូឱ្យបានច្រើន រួចចែករំលែកព័ត៌មានពិតដល់ពួកយើង។» វ៉ាណាសួរបន្ថែមថា៖ «ស្ដាប់ទៅ វាដូចគ្នានឹងការដោះស្រាយរឿង អាថ៌កំបាំងដែរ តើមែនទេម៉ាក់?» «មែនហើយ។ ម៉ាក់មានរបស់ មួយឱ្យកូនមើល។»



ម្ដាយរ៉ាណាទាញប្រអប់មួយចេញពីទូខោអាវ។ «នេះជាម៉ាស៊ីនថតរបស់លោកតាកូន។ គាត់ធ្លាប់ជាអ្នកសារព័ត៌មានរូបថត ហើយគាត់ចូលចិត្តប្រើរូបថតដើម្បីរៀបរាប់ពីដំណើររឿងផ្សេងៗ។» «លោកតាធ្លាប់មានប្រសាសន៍ថា អ្នកសារព័ត៌មានត្រូវចងចាំបីចំនុចសំខាន់គឺ តែងតែចង់ដឹងនិងចង់ឮ ផ្ដល់ព័ត៌មានពិត និងសួរនាំព័ត៌មានពីប្រភពផ្សេងគ្នា។ គាត់តែងតែចង់ឱ្យម៉ាស៊ីនថតនេះមកកូន ដើម្បីឱ្យកូនអាចប្រាប់ពីរឿងរ៉ាវផ្សេងៗដូចគាត់ដែរ។»



នៅថ្ងៃបន្ទាប់ វ៉ាណាយកម៉ាស៊ីនថតនោះដើរទៅផ្សារនៅក្បែរផ្ទះ។ នាងឃើញហ្វូងមនុស្សឈរជុំវិញអ្នកលក់បន្លែតាមរទេះម្នាក់ ដែលមានទឹកមុខក្រៀមក្រំ។ នាងសួរថា៖ «តើពូមានរឿងអី?» ពូអ្នកលក់ឆ្លើយថា៖ «ខ្ញុំបានរុញរទេះលក់បន្លែរបស់ខ្ញុំទៅផ្សារកាលពីព្រឹកមិញ ហើយនៅតាមផ្លូវ ខ្ញុំក៏ឈប់ទិញរបស់ញ៉ាំ។ ប៉ុន្តែពេលត្រឡប់មកវិញ រទេះក៏បាត់ ថ្ងៃនេះខ្ញុំយកផ្លែឃ្លោកមកលក់ផង។»



រ៉ាណាលាន់មាត់ថា៖ «សាច់រឿងនេះអាចជាព័ត៌មានមួយ!» នាងក៏បន្តសួរថា៖ «តើខ្ញុំអាចជួយពូរករទេះនោះមកវិញបានទេ? តើរទេះនោះមានរូបរាងបែបម៉េច?» «អរគុណហើយក្មួយ! វាជារទេះឈើចាស់ ពណ៌ត្នោត និងមានផ្លែឃ្លោកពេញ។»





វ៉ាណានឹកឃើញនូវការណែនាំរបស់ជីតានាង អំពីរបៀបរបបក្នុងការជជីកសួររកព័ត៌មាន។ វ៉ាណាក៏សួរអ្នកលក់ម្នាក់ថាតើគាត់បានឃើញរទេះនោះដែរឬទេ។ មីងនោះតបវិញថា៖ «អត់ឃើញទេ ប៉ុន្តែខ្ញុំឃើញមានផ្លែឃ្លោកជ្រុះលើដីនៅម្ដុំនោះ។» វ៉ាណានិយាយអរគុណ រួចថតរូបដានផ្លែឃ្លោកនោះ។



នៅពេលដើរតាមដានផ្លែឃ្លោក វ៉ាណាបានឃើញប៉ូលីសស្រីម្នាក់ ហើយបានសួរថា តើគាត់បានឃើញរទេះរុញមួយដែរឬទេ។ ប៉ូលីសក៏ឆ្លើយតបភ្លាមថា៖ «ឃើញ! ខ្ញុំឃើញរទេះរុញមួយ។ វាមានពណ៌ខៀវ និងដឹកសុទ្ធតែផ្លែស្វាយពេញ!»



រ៉ាណារំភើបចិត្តណាស់ដែលទទួលបានតម្រុយមួយទៀត។ នាងគិតថានាងនឹងយកព័ត៌មានទៅប្រាប់ម្ចាស់រទេះរុញនោះ ប៉ុន្តែក្រោយមក នាងនឹកឃើញការណែនាំរបស់ជីតាថា «ត្រូវផ្តល់ព័ត៌មានពិត»។ រ៉ាណាបង្ហាញរូបថតដានផ្លែឃ្លោក ហើយនិយាយថា៖ «រទេះដែលខ្ញុំកំពុងរក ជារទេះឈើដឹកបន្លែ និងមានពណ៌ត្នោត។»



«អូ! វាប្រហែលជារទេះមួយផ្សេងទៀតទេ។ ខ្ញុំបានឃើញក្មេងពីរនាក់កំពុងលេងលោតអន្ទាក់នៅជិតរទេះដឹកឃ្លោកមួយនៅឯចុងផ្សារឯនុះ។» ប៉ូលីសនិយាយដោយចង្អុលទៅចុងផ្សារ។



រ៉ាណាហៀបនឹងសួរសំណួរបន្ថែមទៀត ស្រាប់តែនាងឃើញ ក្មេងពីរនាក់រត់ដេញគ្នា។ នាងក៏ចាប់ផ្ដើមថតរូបក្មេងទាំងពីរនាក់ នោះ ហើយនិយាយថា៖ «ប្រាកដជាក្មេងទាំងពីរនោះហើយ។» បន្ទាប់មក នាងក៏ដើរទៅតាមក្មេងទាំងពីរនាក់នោះ។



នៅពេលដែលនាងកំពុងដើរតាមពីក្រោយក្មេងទាំងពីរនាក់នោះ ស្រាប់តែបាត់ស្រមោលពួកគេនៅក្នុងចំណោមតូបលក់ដូរជាច្រើន។ ប៉ុន្តែក្រោយមក នាងបានឃើញក្មេងប្រុសម្នាក់វិញកំពុងរត់ចុះឡើងនៅម្តុំនោះ។



នាងក៏ស្រែកសួរថា៖ «អេ! ខ្ញុំកំពុងព្យាយាមដោះស្រាយរឿង
អាថ៌កំបាំងមួយ។ តើឯងអាចជួយខ្ញុំបានដែរឬទេ?» ក្មេងប្រុស
នោះក៏ឈប់ទ្រឹងនៅមួយកន្លែង ហើយរ៉ាណាសួរបន្ថែមថា៖
«តើឯងបានឃើញរទេះឈើដឹកបន្លែមួយនៅខាងចុងផ្សារដែរ
ឬទេ?» ក្មេងប្រុសនោះឆ្លើយថា៖ «ឃើញ! ខ្ញុំបានយករទេះនោះ
ទៅលេងជាមួយមិត្តរបស់ខ្ញុំម្នាក់ទៀត!»



វ៉ាណា និងក្មេងម្នាក់នោះ នាំគ្នារត់កាត់ផ្សារទៅកាន់កន្លែង
ដែលគេនិងមិត្តភក្តិនាំគ្នាលេងកាលពីព្រឹកមិញ។ នៅទីនោះ
ពួកគេក៏ឃើញរទេះបន្លែពណ៌ត្នោតនៅកាច់ជ្រុងផ្សារ។



រ៉ាណាសម្លឹងមើលរទេះដោយងឿងឆ្ងល់ រួចនិយាយថា៖ «ប្រាកដជារទេះនេះហើយ ប៉ុន្តែហេតុអីបានជាវាមកដល់ទីនេះបាន?»



ក្មេងប្រុសនោះពន្យល់ថា៖ «ពួកខ្ញុំបានឃើញរទេះនោះនៅលើផ្លូវធំទៅផ្សារ ហើយពួកខ្ញុំគិតថា វាជារទេះដែលគេបោះចោល។ ពួកខ្ញុំចង់លេងលោតអន្ទាក់ដែលត្រូវមានគ្នាបីនាក់ ប៉ុន្តែយើងមានគ្នាតែពីរនាក់។ ដូច្នេះយើងក៏រុញរទេះទៅមកកន្លែងនេះ ហើយចងកៅស៊ូទៅនឹងជើងរទេះរុញ ដើម្បីធ្វើជាអ្នកលេងម្នាក់ទៀត។»



រ៉ាណាលាន់មាត់ថា៖ «មែនហើយ! រទេះនេះប្រាកដជារអិលធ្លាក់ចុះពីទួល នៅពេលដែលពូអ្នកលក់ឈប់សម្រាកញ៉ាំបាយ។ គាត់រកវាមិនឃើញ ព្រោះឯងរុញវាមកទីនេះ ដោយមិនដឹងថាម្ចាស់គេកំពុងតែតាមរក!»





នាងបានសុំឱ្យក្មេងប្រុសទាំងពីរនាក់ជួយរុញរទេះទៅរក ពូអ្នកលក់វិញ។ ម្ចាស់រទេះត្រេកអរណាស់ដែលបានរទេះ ត្រឡប់មកវិញ ហើយមហាជនក៏រីករាយដែរ ដោយបានដឹងថា នោះមិនមែនជាអំពើចោរកម្ម។



វ៉ាណាពន្យល់អំពីដំណើរដើមទងនៃរឿងនេះឱ្យគ្រប់គ្នាបានដឹង ដោយបង្ហាញរូបភាពដែលនាងបានថត និងរៀបរាប់ពីអ្នកដែលនាងបានសួរនាំ។



មនុស្សម្នាក់នៅពីក្រោយវ៉ាណា និយាយឡើងថា៖ «នេះជាព័ត៌មានដ៏អស្ចារ្យ!» វ៉ាណាងាកទៅក្រោយ ហើយឃើញអ្នកសារព័ត៌មានដែលនាងធ្លាប់ឃើញក្នុងទូរទស្សន៍។ «ប្អូនស្រីជាអ្នកចង់ដឹងចង់ឮ មានភាពស្មោះត្រង់ ហើយប្អូនបានសួរនាំព័ត៌មានពីប្រភពផ្សេងគ្នា ដើម្បីស្វែងរកការពិត។ តើប្អូនអាចទៅស្ថានីយទូរទស្សន៍ជាមួយបងបានដែរទេ? បងចង់ឱ្យប្អូននិយាយរៀបរាប់អំពីដំណើររឿងនេះ ដើម្បីចាក់ផ្សាយព័ត៌មាននៅក្នុងយប់នេះ។»



នៅថ្ងៃនោះ រ៉ាណាបានក្លាយជាអ្នកសារព័ត៌មានម្នាក់យ៉ាងពិតប្រាកដ។ គេបានចុះផ្សាយសាច់រឿងនេះ និងរូបភាពដែលនាងបានថត ដាក់ក្នុងផ្នែកមួយនៃកម្មវិធីព័ត៌មាន ស្ដីអំពី «សហគមន៍ចេះជួយយកអាសាគ្នា»។



មិនតែប៉ុណ្ណោះ វ៉ាណាក៏ត្រូវបានគេសម្ភាសផ្សាយតាមទូរទស្សន៍ទៀតផង!



មុននឹងបញ្ចប់ការសម្ភាស រ៉ាណាបានផ្ដាំផ្ញើថា៖ «សូមស្វែងរកព័ត៌មានគ្រប់ពេលវេលា បើមិនដូច្នោះទេ អ្នកនឹងមិនដឹងពីអ្វីដែលកំពុងកើតឡើងជុំវិញខ្លួនអ្នកឡើយ!»

Generously supported by Smart Axiata

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ព័ត៌មានទាន់ហេតុការណ៍ (Breaking News!)*, Author: The Asia Foundation - Let's Read. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/